ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ : ២២៤៧.....អ.រតន.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ១១ ឆ្នាំ ២០១០

សេចក្តីណែនាំ
ស្តីពី
ការបិទបញ្ជីគណនេយ្យរដ្ឋ គណនេយ្យថវិការាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០១០ និង ការអនុវត្តឆ្នាំ ២០១១

យោងប្រកាសណែនាំលេខ ៥២៨ សហវ.ថ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១០ ស្តីពីការបិទបញ្ជីចំណូល ចំណាយ និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០១០ ។

ដើម្បីលើកកំពស់បន្ថែមទៀតលើការងារបិទបញ្ជីគណនេយ្យ នៃការិយបរិច្ឆេទ ២០១០ និង ការងារត្រូវបំពេញនៅឆ្នាំ ២០១១ របស់រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី-ខេត្ត អគ្គនាយកដ្ឋានរតនាគារជាតិសូមចេញសេចក្តីណែនាំ សម្រាប់អនុវត្តដូចមានខ្លឹមសារខាងក្រោមនេះ :

I-សម្រាប់ការិយបរិច្ឆេទ ២០១០

១- ថវិការដ្ឋ

ក- នៅរតនាគារថ្នាក់កណ្តាល :

ក.១- ប្រាក់ចំណូលទាំងអស់ត្រូវប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតនៅត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ។

ក.២-រតនាគារថ្នាក់កណ្តាលត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់សម្រាប់ឆ្នាំ ២០១០ នៅវេលាម៉ោង ១៧ និង ៣០ នាទី ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ។

ក.៣-រតនាគារថ្នាក់កណ្តាលត្រូវបញ្ឈប់ការដកប្រាក់រដ្ឋទេយ្យបុរេប្រទាននៅម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០ ។ សាច់ប្រាក់រដ្ឋទេយ្យបុរេប្រទានដែលក្រសួង ស្ថាប័ន អង្គភាព ចំណាយសល់ត្រូវយកមកបង់ចូលរតនាគារថ្នាក់កណ្តាលអោយបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ។

ក.៤-ក្រោយពីបានទទួលរបាយការណ៍លំអិតស្តីពីចំណូល ចំណាយថវិកាពីរតនាគាររាជធានី-ខេត្ត នាយកដ្ឋានចំណូលចំណាយថវិកា ត្រូវបង្កើតរបាយការណ៍សរុបស្តីពីចំណូល ចំណាយថវិកាទូទាំងប្រទេស (ថ្នាក់កណ្តាល និង រាជធានី-ខេត្ត) ។ របាយការណ៍លំអិតចំណូល ចំណាយថវិកា ត្រូវធ្វើការផ្គូផ្គងជាមួយតារាងតុល្យភាពគណនីទៅតាមគណនី និង អនុគណនី ។

ក.៥ -នៅដំណាច់ឆ្នាំ នាយកដ្ឋានចំណូល ចំណាយថវិកាត្រូវផ្ទេរសមតុល្យឥណទាយី (ពិត) នៃ គណនីចំណូលថវិកា

ចរន្ត (លេខ ៧..) ទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ (លេខ ១២១) ។

ក.៦-នៅដំណាច់ឆ្នាំ នាយកដ្ឋានគណនេយ្យត្រូវផ្ទេរសមតុល្យឥណទាយីនៃអនុគណនី ការសង និងការបង្វិលវិញ (លេខ ៦៤១៩, ៦៤២៩, ៦៤៣៩, ៦៤៤៩ និង ៦៤៥៩) នៅថ្នាក់កណ្តាលទៅគណនីចំណាយថវិកាដែលពាក់ព័ន្ធ (លេខ ៦៤..) ។

ក.៧-នាយកដ្ឋានចំណូល ចំណាយថវិកាត្រូវផ្ទេរសមតុល្យ ឥណយិក (ពិត)នៃអនុគណនីចំណាយថវិកា (លេខ ៦..និងលេខ ៧០៩) ទៅគណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ១២១) ។

ក.៨- ក្រោយពីបានទទួលប្រកាសផ្ទេរលទ្ធផលពីរតនាគាររាជធានី-ខេត្ត នាយកដ្ឋានគណនេយ្យត្រូវធ្វើមជ្ឈការតួលេខទាំងនោះទៅក្នុងគណនីលទ្ធផលនៃការិយបរិច្ឆេទនៅថ្នាក់កណ្តាលតាមរយៈគណនីទំនាក់ទំនង ដើម្បីមានតួលេខសរុបទូទាំងប្រទេស ។

ក.៩-នាយកដ្ឋានគណនេយ្យត្រូវបង្កើតតារាងតុល្យភាពគណនីរបស់រតនាគារថ្នាក់កណ្តាល តារាងតុល្យភាពគណនីសរុបរាជធានី-ខេត្ត តារាងតុល្យភាពគណនីទូទាំងប្រទេស (ថ្នាក់កណ្តាល និង រាជធានី-ខេត្ត)តារាងតុល្យការ គណនីលទ្ធផលប្រចាំឆ្នាំ និងតារាងរាយលំអិតលទ្ធផលនៃការអនុវត្តថវិការដ្ឋទូទាំងប្រទេសយ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ។

ក.១០-នៅដំណាច់ឆ្នាំ នាយកដ្ឋានគណនេយ្យត្រូវបង្កើតតារាងផ្គូផ្គងសមតុល្យគណនីប្រាក់បញ្ញើ (លេខ ៤០៩, ៤៦៧ , ៤៥0, ៤៥១, ៤៥២ ,៥១0 , ៥១៣, ៥១៤) គណនីប្រាក់ខ្ចី (លេខ ១៦)ប្រាក់អោយខ្ចី (លេខ ២៧១)ជាមួយអង្គភាពពាក់ព័ន្ធ ។

ក.១១- រតនាគាររាជធានី-ខេត្ត ត្រូវធ្វើតារាងផ្គូផ្គងតួលេខអនុវត្តចំណូល ចំណាយជាមួយមន្ទីរជំនាញខេត្ត សាលារាជធានី-ខេត្ត រួចផ្ញើមកអគ្គនាយកដ្ឋានរតនាគារជាតិ អោយបានមុនថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១១ ។

ខ -នៅរតនាគាររាជធានី- ខេត្ត :

ខ.១- ប្រាក់ចំណូលទាំងអស់ត្រូវប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតនៅត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១0 ។

ខ.២-រតនាគាររាជធានី-ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់សម្រាប់ឆ្នាំ ២០១0 នៅវេលាម៉ោង ១៧ និង ៣0 នាទី ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១0 ។ ម្យ៉ាងទៀតរតនាគាររាជធានី-ខេត្ត ត្រូវត្រួតពិនិត្យតារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទាន អោយបានត្រឹមត្រូវដើម្បីមានលក្ខណៈងាយស្រួលលើការផ្គូផ្គងតួលេខ នៃអនុគណនីបេឡា(លេខ ៥៣) ជាមួយសាច់ប្រាក់ដែលរជ្ជទេយ្យករត្រូវយកមកបង់ចូលថវិកា ។

ខ.៣-រតនាគាររាជធានី-ខេត្ត ត្រូវបញ្ឈប់ការដកប្រាក់រជ្ជទេយ្យបុរេប្រទាននៅម៉ោង ១៧ និង ៣0 នាទី នាថ្ងៃទី ១0 ខែ ធ្នូ ឆ្នាំ ២០១0 ។ សាច់ប្រាក់រជ្ជទេយ្យបុរេប្រទានដែលមន្ទីរ អង្គភាពចំណាយសល់ត្រូវយកមកបង់ចូលរតនាគាររាជធានី-ខេត្ត អោយបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១0 ។ មន្ទីរ សាលារាជធានី-ខេត្ត ត្រូវធ្វើតារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទានមករតនាគាររាជធានី-ខេត្ត អោយបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១0 ។

ខ.៨-រតនាគាររាជធានី-ខេត្ត ត្រូវខិតខំដោះស្រាយធ្វើអោយគណនីដូចខាងក្រោមនេះសូន្យសមតុល្យនៅដំណាច់ឆ្នាំ ២០១០ :

- គណនី ចំណូលផ្សេងៗ និង បង្វែរវង់ចាំដោះស្រាយ (លេខ ៤៧០.៨)(លើកលែងចំណូលផ្ទេរពីអង្គភាពគយ និង រដ្ឋាករ និងអង្គភាព ពន្ធដារមកទុកជាបណ្តោះអាសន្ន)
- គណនី ចំណូលបណ្តោះអាសន្ន (គយ និង ពន្ធ) (លេខ ៤៧១)
- គណនី ចំណូលបានទទួលពុំទាន់មានសលាកប័ត្រ (លេខ ៤៧៤)
- គណនី រដ្ឋទេយ្យករចំណូល (លេខ ៤៧៧)
- គណនី រដ្ឋទេយ្យកបុរេប្រទាន (លេខ ៥៤៣ និង ៥៤៤) ។

ខ.៥-ត្រូវធ្វើការផ្តុំផ្តងសមតុល្យឥណាយិកនៃគណនីចរន្តនៅរតនាគាររាជធានី-ខេត្ត ជាមួយសមតុល្យឥណទាយីនៃគណនីចរន្តនៅសាខាធនាគារជាតិនៃកម្ពុជា ឬ សាខាធនាគារពាណិជ្ជ ។

ខ.៦- រាល់ការកាត់ពន្ធ (VAT)ពីអាណត្តិបើកប្រាក់របស់ឃុំសង្កាត់ត្រូវធ្វើការផ្ទេរប្រាក់ពីគណនីចរន្តសម្រាប់ចំណូលចំណាយឃុំ សង្កាត់ ទៅគណនីចរន្តសម្រាប់ចំណូល ថវិការដ្ឋ និង រាជធានី-ខេត្ត យ៉ាងយឺតបំផុតនៅដំណាច់ខែ ។

ខ.៧-រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី-ខេត្ត ត្រូវរិះរកគ្រប់មធ្យោបាយក្នុងការផ្តល់តួលេខប្រកាសផ្ទេរប្រាក់ ផ្ទេរការទូទាត់ទៅរតនាគាររាជធានី-ខេត្ត និងទទួលមកវិញអោយបានឆាប់រហ័សដើម្បីសម្រួលដល់ការចុះបញ្ជី នៅដំណាច់ឆ្នាំ ក្នុងគោលបំណងបញ្ចូលអោយអស់នូវប្រតិបត្តិការរបស់ឆ្នាំ ២០១០ ។

ខ.៨-សមតុល្យនៃអនុគណនីរង "ទំនាក់ទំនងរវាងរតនាគាររាជធានី-ខេត្ត និងរតនាគារថ្នាក់កណ្តាល លើការផ្ទេរសាច់ប្រាក់ (លេខ ៤៥៨.២.៣) ត្រូវផ្ទេរទៅអនុគណនីរង"ទំនាក់ទំនងរវាងរតនាគាររាជធានី-ខេត្ត និងរតនាគារថ្នាក់កណ្តាលលើសមតុល្យឆ្នាំមុន "(លេខ ៤៥៨.២.៥)នៅពេលបិទបញ្ជី ដំណាច់ឆ្នាំ ក្រោយពីមានការផ្តុំផ្តងរវាងរតនាគារថ្នាក់កណ្តាល និង រតនាគារថ្នាក់រាជធានី-ខេត្ត ត្រឹមត្រូវហើយ ។

ខ.៩-សមតុល្យនៃអនុគណនីរង "ទំនាក់ទំនងរវាងរតនាគាររាជធានី-ខេត្ត និងរតនាគារថ្នាក់កណ្តាលលើប្រតិបត្តិការផ្សេងៗ (លេខ ៤៥៨.២.៤) ត្រូវផ្ទេរទៅអនុគណនីរង " ទំនាក់ទំនងរវាងរតនាគាររាជធានី-ខេត្ត និងរតនាគារថ្នាក់កណ្តាលសមតុល្យឆ្នាំមុន (លេខ ៤៥៨.២.៥)ក្រោយពីបានផ្តុំផ្តងជាមួយរតនាគារថ្នាក់កណ្តាលយ៉ាងយឺតបំផុតត្រឹមដំណាច់ខែ មករា ឆ្នាំ ២០១០ ។

ខ.១០-មុនគណនារកលទ្ធផលនៃការអនុវត្តថវិកាចរន្ត ត្រូវផ្ទេរសមតុល្យឥណទាយី នៃគណនីចំណូលពីការសង និងការបង្វិលវិញ (លេខ ៦៤១៩ ,៦៤២៩, ៦៤៣៩, ៦៤៤៩ និង ៦៤៥៩ ទៅគណនីចំណាយថវិកាពាក់ព័ន្ធ(លេខ៦៤) ។

ខ.១១-បន្ទាប់មកត្រូវផ្ទេរសមតុល្យឥណាយិក(ពិត) នៃគណនីចំណាយថវិកាចរន្ត (លេខ ៦ .....) និង សមតុល្យឥណទាយី(ពិត)នៃគណនីចំណូលថវិកាចរន្ត (លេខ៧.)ទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ (លេខ១២១) ។ លទ្ធផលដែលទទួលបាន គឺឱនភាព ឬ អតិរេក ។

ខ.១២-រតនាគាររាជធានី-ខេត្ត ត្រូវផ្ទេរសមតុល្យគណនីលទ្ធផលនៃការអនុវត្តថវិការដ្ឋ (អតិរេក ឬឱនភាព) មករតនាគារថ្នាក់កណ្តាលតាមរយៈគណនីទំនាក់ទំនង (លេខ ៤៥៨.២.៤) នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០។

ខ.១៣-នៅដំណាច់ឆ្នាំ រតនាគាររាជធានី-ខេត្ត ត្រូវបង្កើតតារាងដូចខាងក្រោម ៖

- តារាងតុល្យភាពគណនីមុនគណនារកលទ្ធផល (គណនី ចំណូលពីការសង និងការបង្វិលវិញមានសមតុល្យស្មើសូន្យ រីឯគណនីចំណូល គណនីចំណាយថវិកាចរន្តពិត នៅមានសមតុល្យ)។
- តារាងតុល្យភាពគណនីក្រោយគណនារកលទ្ធផល (គណនីចំណូលថវិកា គណនីចំណាយថវិកាចរន្ត និង គណនីលទ្ធផលមានសមតុល្យស្មើសូន្យ)។
- តារាងតុល្យភាពគណនីប្រចាំឆ្នាំ (តារាងតុល្យភាពគណនី ៦ ចន្លោះ)
- របាយការណ៍លទ្ធផលការអនុវត្តថវិកាចរន្ត ប្រចាំឆ្នាំ។
- តារាងយោងសមតុល្យឆ្នាំ ២០១០ ទៅឆ្នាំ ២០១១។

ខ.១៤-នៅដំណាច់ឆ្នាំ រតនាគាររាជធានី-ខេត្ត ត្រូវបង្កើតតារាងលទ្ធផលប្រចាំឆ្នាំ រួចផ្ញើមករតនាគារថ្នាក់កណ្តាល។

ខ.១៥-រតនាគាររាជធានី-ខេត្ត ត្រូវបង្កើតតារាងផ្ទូផ្តងសមតុល្យគណនីប្រាក់បញ្ញើ មានជាអាទិ៍គណនីលេខ ៤២១, ៤៤១, ៤៤២, ៤៥0, ៤៥១, ៤៥២, ៤៥៣, ៤៦២, ៤៦៧, ៥១0, ៥១៧។

២- ថវិការាជធានី- ខេត្ត :

២.១-ការគណនារកលទ្ធផលនៃការអនុវត្តថវិកាចរន្ត ដោយផ្ទេរសមតុល្យឥណទាយីនៃគណនីចំណូលពីការសង និងការបង្វិលវិញ (លេខ ៦៤១៩, ៦៤២៩, ៦៤៣៩, ៦៤៤៩ និង ៦៤៥៩ ទៅគណនីចំណាយថវិកាពាក់ព័ន្ធ (លេខ ៦៤)។

២.២-បន្ទាប់មកផ្ទេរសមតុល្យឥណយិក (ពិត)នៃគណនីចំណាយថវិកាចរន្ត (លេខ ៦...)និងសមតុល្យឥណទាយី (ពិត)នៃគណនីចំណូលថវិកាចរន្ត (លេខ ៧ ..) ទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ (លេខ ១២១)។ លទ្ធផលដែលទទួលបាន គឺ អតិរេក ។

២.៣-រតនាគាររាជធានី-ខេត្ត ត្រូវរៀបចំរបាយការណ៍លទ្ធផលមុនផ្ទេរអតិរេកចូលថវិការដ្ឋ។

២.៤-រតនាគាររាជធានី-ខេត្ត ត្រូវផ្ទេរតួលេខសរុបចំណាយវិនិយោគដោយរាជធានី-ខេត្ត (លេខ ២)ពី គណនីលទ្ធផលអតិរេករបស់ថវិការាជធានី-ខេត្ត ទៅគណនី ធនបំរុង :

ឥណពន្ធ គណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ១២១)

ឥណទាន គណនី ធនបំរុង (លេខ ១0៦)។

២.៥-ចំពោះរតនាគារខេត្តសៀមរាប និង បាត់ដំបងត្រូវផ្ទេរលទ្ធផលនៃការិយបរិច្ឆេទ (ឱនភាព)របស់ថវិកាក្រុងសៀមរាប និង ក្រុងបាត់ដំបង ទៅគណនី លទ្ធផលនៃការិយបរិច្ឆេទរបស់ថវិកាខេត្ត។

លេខនាក្នុងគណនេយ្យថវិកាខេត្ត:

ឥណពន្ធ គណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ១២១)

ឥណទាន គណនី ទំនាក់ទំនងរវាងថវិកាខេត្ត និង ថវិកាក្រុង (លេខ ៤៥៧) ។

២.៦-រតនាគាររាជធានី-ខេត្ត ត្រូវផ្ទេរលទ្ធផលអតិរេកចុងក្រោយរបស់ថវិការាជធានី-ខេត្ត ចូលថវិការដ្ឋ ។

លេខនាក្នុងគណនេយ្យថវិកាខេត្ត :

ឥណពន្ធ គណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ១២១)

ឥណទាន គណនី ប្រាក់បញ្ញើនៅរតនាគារ (លេខ ៥១៥)

លេខនាក្នុងគណនេយ្យរដ្ឋ :

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការាជធានី-ខេត្ត (លេខ ៤៤២)

ឥណទាន គណនី ចំណូលពីការបង់ អតិរេករបស់ថវិការាជធានី-ខេត្ត (លេខ ៧៧១១) ។

២.៧-នៅដំណាច់ឆ្នាំ រតនាគាររាជធានី-ខេត្ត ត្រូវបង្កើតតារាងដូចខាងក្រោម ៖

-តារាងតុល្យភាពគណនីមុនគណនារកលទ្ធផល (គណនី ចំណូលពីការសង និងការបង្វិលវិញមានសមតុល្យស្មើសូន្យ រីឯគណនីចំណូល គណនីចំណាយថវិកាចរន្តពិត នៅមានសមតុល្យ) ។

-តារាងតុល្យភាពគណនីក្រោយគណនារកលទ្ធផល (គណនីចំណូលថវិកា គណនីចំណាយថវិកាចរន្ត និងគណនីលទ្ធផល មានសមតុល្យស្មើសូន្យ) ។

- តារាងតុល្យភាពគណនីប្រចាំឆ្នាំ (តារាងតុល្យភាពគណនី ៦ ចន្លោះ)

- របាយការណ៍លទ្ធផលប្រចាំឆ្នាំ

- តារាងយោងសមតុល្យឆ្នាំ ២០១០ ទៅឆ្នាំ ២០១១ ។

៣- ថវិកាក្រុងស្ទឹមវាប និង ក្រុងបាត់ដំបង :

៣.១-គណនារកលទ្ធផលនៃការអនុវត្តថវិកាចរន្ត ដោយផ្ទេរសមតុល្យឥណទាយីនៃគណនីចំណូលពីការសង និង ការបង្វិលវិញ (លេខ ៦៤១៩ , ៦៤២៩, ៦៤៣៩, ៦៤៤៩, និង ៦៤៥៩ ទៅគណនីចំណាយថវិកាពាក់ព័ន្ធ (លេខ ៦៤...) ។

៣.២-បន្ទាប់មកផ្ទេរសមតុល្យឥណាយិក(ពិត)នៃគណនីចំណាយថវិកាចរន្ត (ថ្នាក់ ៦...)និងសមតុល្យឥណទាយី (ពិត)នៃគណនីចំណូលថវិកាចរន្ត (ថ្នាក់ ៧ ..) ទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ (លេខ ១២១) ។ លទ្ធផលដែលទទួលបាន គឺ ឱភាព ។

៣.៣-រតនាគារខេត្ត ស្ទឹមវាប និង បាត់ដំបងត្រូវកត់ត្រាចំនួនទឹកប្រាក់ចំណាយវិនិយោគរបស់ថវិកាក្រុង (ប្រសិនជាមាន) ទៅគណនីឧបត្ថម្ភកធនវិនិយោគ (លេខ ១៣១១) ។

លេខនាគណនេយ្យថវិកាក្រុង :

ឥណពន្ធ គណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ១២១)

ឥណទាន គណនី ចំណូល ពីឧបត្ថម្ភនិយោគ (លេខ ១៣១១) ។

៣.៤-រតនាគារខេត្តស្ទៀមរាប និងបាត់ដំបងត្រូវផ្ទេរលទ្ធផលចុងក្រោយនៃការិយបរិច្ឆេទ (ឱនភាព) របស់ថវិកាក្រុងទៅគណនី លទ្ធផលនៃការិយបរិច្ឆេទរបស់ថវិកាខេត្ត ។

លេខនាក្នុងគណនេយ្យថវិកាក្រុង :

ឥណពន្ធ គណនី ទំនាក់ទំនងរវាងថវិកាក្រុង និង ថវិកាខេត្ត (លេខ ៤៥៧)

ឥណទាន គណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ១២១) ។

៣.៥-ត្រូវបង្កើតតារាងតុល្យភាពគណនីមុន និងក្រោយផ្ទេរលទ្ធផល និងរបាយការណ៍លទ្ធផលរបស់ថវិកាក្រុង និងតារាងយោងសមតុល្យឆ្នាំ ២០១០ ទៅឆ្នាំ ២០១១ ។

II-ការអនុវត្តនៅឆ្នាំ ២០១១

១- អនុគណនីទំនាក់ទំនងរវាងរតនាគារថ្នាក់កណ្តាល និង រតនាគាររាជធានី-ខេត្ត ប្រតិបត្តិការផ្សេងៗ ត្រូវបំបែកទៅជា អនុគណនីរងបន្តដូចខាងក្រោម ៖

- អនុគណនីទំនាក់ទំនងរវាងរតនាគារថ្នាក់កណ្តាល និង រតនាគាររាជធានី-ខេត្ត ប្រតិបត្តិការផ្សេងៗ ឆ្នាំនេះ មានលេខសម្គាល់ ៤៥៨.១.៤.**១០**
- អនុគណនីទំនាក់ទំនងរវាងរតនាគារថ្នាក់កណ្តាល និង រតនាគាររាជធានី-ខេត្ត ប្រតិបត្តិការផ្សេងៗ ឆ្នាំមុន មានលេខសម្គាល់ ៤៥៨.១.៤.**១១**
- អនុគណនីទំនាក់ទំនងរវាងរតនាគាររាជធានី-ខេត្ត និងរតនាគារថ្នាក់កណ្តាល ប្រតិបត្តិការផ្សេងៗ ឆ្នាំនេះ មានលេខសម្គាល់ ៤៥៨.២.៤.**១០**
- អនុគណនីទំនាក់ទំនងរវាងរតនាគាររាជធានី-ខេត្ត និង រតនាគារថ្នាក់កណ្តាល ប្រតិបត្តិការផ្សេងៗ ឆ្នាំមុន មានលេខសម្គាល់ ៤៥៨.២.៤.**១១**

៣-នៅពេលមានការទូទាត់ប្រាក់បុរេប្រទានដោយបង់ជាប្រាក់ នាយកដ្ឋានគណនេយ្យត្រូវផ្តល់លិខិតជូនដំណឹងឥណទានទៅនាយកដ្ឋានចំណូល ចំណាយថវិកាជាតិ ចំនួន ០១ ច្បាប់ ដើម្បីកត់ត្រាបន្ថយ ប្រាក់បុរេប្រទាន ។

៤- ការកត់ត្រាការបង់សំណោះចំណាយនៅរតនាគារថ្នាក់កណ្តាល និង នៅរតនាគាររាជធានី-ខេត្ត ត្រូវអនុវត្តទៅតាមការកំណត់ដូចខាងក្រោមនេះ :

- សំណោះចំណាយលើប្រាក់ប្បៀវត្សដែលបានបង់ក្នុងឆ្នាំត្រូវកត់ត្រាទៅក្នុងគណនីការសង និងការបង្វិលវិញ ។

លេខនាគណនេយ្យ :

ឥណពន្ធ គណនី ហិរញ្ញវត្ថុ (លេខ ៥....)

ឥណទានគណនី ការសង និង ការបង្វិលវិញ (លេខ ៦៤១៩ .../៦៤២៩.....) ។

- សំណោះចំណាយប្រាក់ប្បៀវត្សរបស់ឆ្នាំមុន (បានបង់ឆ្លងឆ្នាំ) ត្រូវចាត់ជាចំណូលថវិកាក្នុងឆ្នាំកំពុងអនុវត្ត ។

លេខនាគណនេយ្យ :

ឥណពន្ធ គណនី ហិរញ្ញវត្ថុ (លេខ ៥....)

ឥណទានគណនី ចំណូលថវិកា (លេខ. ៧៦៨) ។

- សំណោះចំណាយ របស់ឆ្នាំកំពុងអនុវត្ត ក្រៅពីប្រាក់ប្បៀវត្ស (បានបង់ក្នុងឆ្នាំ) ត្រូវកត់ត្រាបន្ថយចំណាយថវិកា ដែលបានបើកផ្តល់ ។

លេខនាគណនេយ្យ :

ឥណពន្ធ គណនី ហិរញ្ញវត្ថុ (លេខ ៥....)

ឥណទានគណនី ចំណាយថវិកា (លេខ ៦...) ។

- សំណោះចំណាយ របស់ឆ្នាំមុន ក្រៅពីប្រាក់ប្បៀវត្ស (បានបង់ឆ្លងឆ្នាំ) ត្រូវចាត់ជាចំណូលថវិកាក្នុងឆ្នាំកំពុងអនុវត្ត ។

លេខនាគណនេយ្យ :

ឥណពន្ធ គណនី ហិរញ្ញវត្ថុ (លេខ ៥....)

ឥណទាន គណនី ចំណូលថវិកា (លេខ ៧៦៨) ។

៥-រតនាគាររាជធានី-ខេត្ត ត្រូវធ្វើការផ្តួផ្តងរបាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែ ឆ្នាំ ជាមួយតារាងតុល្យភាពគណនីតាមគណនី និងអនុគណនី។ នៅពេលមានការកែតម្រូវតួលេខ ត្រូវជូនដំណឹងដល់នាយកដ្ឋានដែលពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានរតនាគារជាតិ ។

៦-រតនាគាររាជធានី-ខេត្តត្រូវស្វែងយល់អោយបានច្បាស់អំពីការប្រើប្រាស់មាតិកាថវិកានិងមាតិកាគណនីព្រមទាំងមានការប្រុងប្រយ័ត្នលើការប្រើប្រាស់គណនី ឬ អនុគណនីលើអាណត្តិបើកប្រាក់ អោយមានសង្គតភាពរវាងអនុគណនី លើអាណត្តិបើកប្រាក់ និងឯកសារធានាចំណាយ ឬ លិខិតយុត្តិការចំណាយ..... ។

៧-ការទូទាត់អាណត្តិបើកប្រាក់ចេញនៅរាជធានី-ខេត្ត ផ្ទេរមករតនាគារថ្នាក់កណ្តាលត្រូវឆ្លងកាត់គណនី អ្នកផ្តត់ផ្គង់ (លេខ ៤០១) ឬ គណនី បេសកកម្ម និង សោហ៊ុយផ្សេងៗត្រូវសង (លេខ ៤២២) សិន ។

៨- សាខាធនាគារជាតិនៃកម្ពុជា នៅរាជធានី-ខេត្ត នឹងប្តូរលេខគណនីចរន្តរបស់រតនាគាររតនាគាររាជធានី-ខេត្ត នៅដើមឆ្នាំ ២០១១ ។ ក្រោយពីមានការប្តូរលេខគណនី រតនាគាររាជធានី-ខេត្ត ត្រូវជូនដំណឹងមកនាយកដ្ឋានគណនេយ្យជាបន្ទាន់ដើម្បីមានមូលដ្ឋានលើការផ្ទេរប្រាក់ ។

៩-គណនេយ្យករត្រូវពិនិត្យអោយបានហ្មត់ចត់លើ តួលេខលើបញ្ជីវិភាគត្រូវដូចគ្នានឹងតួលេខរបស់តារាងសរុបវិភាគ សមតុល្យជាលេខត្រូវស៊ីគ្នានឹងសមតុល្យជាអក្សរ និង តួលេខចុងគ្រាដែលបានយោងត្រូវដូចគ្នានឹងតួលេខដើមគ្រា ។

១០- មុនធ្វើការទូទាត់ជូនអ្នកផ្គត់ផ្គង់ អ្នកម៉ៅការ រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី-ខេត្ត ត្រូវពិនិត្យ កាតព្វកិច្ចនៃការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យា។ ក្នុងករណីដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការ ពុំទាន់បានបង់ពន្ធប្រថាប់ត្រាទេ រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី-ខេត្ត ត្រូវជម្រុញអោយមានការបង់ពន្ធទើបធ្វើការទូទាត់។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានរតនាគារជាតិ លោក លោកស្រី ប្រធានរតនាគាររាជធានី-ខេត្ត ចាត់ចែងអនុវត្តតាមខ្លឹមសារដូចមានខាងលើអោយទទួលបានលទ្ធផលល្អប្រសើរ។

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយករងអគ្គនាយកដ្ឋានរតនាគារជាតិ

ជិន ឃុន

ចំលងជូន :

- លេខាធិការដ្ឋាន នៃ គណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- នាយកដ្ឋានថវិកា
- នាយកដ្ឋានគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

" ដើម្បីជ្រាប "